**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាល**

**THE ARBITRATION COUNCIL**

លេខ និង ឈ្មោះសំណុំរឿង : ២៩/១០-មិញ ហ៊ុយ ហ្គាមេន

កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ : ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក: កៅ ថាច

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: អន ណន

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ: ប៉ែន ប៊ុនឈា

## ភាគីវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន

អាសយដ្ឋាន : ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៧១៥ ៧១៥ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ស៊ុន ធារ័ត្ន រដ្ឋបាល

២- កញ្ញា ហម ដាវី រដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : សហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ មិញ ហ៊ុយ ហ្គាមេន

អាសយដ្ឋាន : ផ្ទះលេខ ១៦ បេ ផ្លូវលេខ ៣៦០ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ២៦៣ ៩៨៣ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ប៉ាវ ស៊ីណា    មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

២- លោក ហ៊្វា សាលី    មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនចេញថ្លៃពិនិត្យសុខភាព ពិនិត្យឈាមជូនកម្មករ និងដឹកជញ្ជូនកម្មករទៅពិនិត្យ ហើយចេញលុយសងកម្មករដែលបានទៅពិនិត្យពេលមុន។ ដោយឡែកភាគីក្រុមហ៊ុនសុំអនុវត្តតាមច្បាប់ ដោយក្រុមហ៊ុនគិតចាប់ពីថ្ងៃផ្សះផ្សានេះតទៅ ហើយចំពោះការទូទាត់សងថ្លៃពិនិត្យសុខភាពពេលមុន គឺក្រុមហ៊ុនមិនអាចផ្តល់ជូនបានទេ។

២- ចំពោះធ្វើការងារនៅថ្ងៃបុណ្យ និងថ្ងៃអាទិត្យគុណនឹងបី ក្រុមហ៊ុនត្រូវបូកចូលក្នុងប្រាក់ខែ និងថែមម៉ោង ពីម៉ោង ១៦:០០ ដល់ម៉ោង ២០:០០ ហើយត្រូវឱ្យកម្មករសំរាលសាមសិបនាទី និងអាហារមួយប្រអប់ ឬថែមម៉ោងមួយម៉ោង ១០០០ រៀល។ ដោយឡែកភាគីក្រុមហ៊ុនសុំអនុវត្តតាមច្បាប់ និងយោងតាមសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០។

៣- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនរៀបចំបើកប្រាក់ឈ្នួលឱ្យចប់សព្វគ្រប់ត្រឹមម៉ោង១៦:០០ល្ងាច និងបើកសងវិញភ្លាមៗនៅពេលគិតលុយបាត់។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអាចបើកជូននូវប្រាក់ឈ្នួលត្រឹមម៉ោង ១៦:០០ ល្ងាចបាន តែបើមានការយឺតយ៉ាវ គឺម្តងម្កាលតែប៉ុណ្ណោះ។ រីឯការគិតលុយបាត់ជូនកម្មករ (សងវិញ) ភ្លាមៗនោះ គឺក្រុមហ៊ុនមិនអាចធ្វើការបើកសងវិញភ្លាមៗបានទេ គឺក្រុមហ៊ុនគិតបើកសងវិញក្នុងរយៈពេលប្រាំពីរថ្ងៃ គិតចាប់ពីថ្ងៃបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ។

៤- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនធ្វើកិច្ចសន្យាការងារចំពោះកម្មករប្រុសចាប់ពី៦ខែឡើងទៅ។ ដោយឡែកភាគីក្រុមហ៊ុនសុំអនុវត្តតាមមាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ។

៥- នៅពេលកម្មករនិយោជិតឈឺ ហើយមានសំបុត្រពេទ្យបញ្ជាក់ត្រឹមត្រូវ ក្រុមហ៊ុនមិនត្រូវកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ឡើយ។ ដោយឡែកភាគីក្រុមហ៊ុនមិនកាត់ប្រាក់ឈ្នួលទេ តែក្រុមហ៊ុនសុំកាត់ប្រាក់រង្វាន់ ដោយសារថាប្រាក់រង្វាន់នេះ ជាប្រាក់សម្រាប់កម្មករនិយោជិតមកធ្វើការទៀងទាត់ (យោងសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០)។

៦- ចំពោះករណីថ្នាក់ដឹកនាំសហជីព ៣ រូប ដែលក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាការងារ បងប្អូននៅតែទាមទារឱ្យក្រុមហ៊ុនទទួលយកចូលធ្វើការជាធម្មតាវិញ និងញែកឱ្យដាច់ដោយឡែកពីវិវាទការងាររួម។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនពុំបានបញ្ចប់សកម្មភាពរបស់សហជីពទេ គឺក្រុមហ៊ុនបញ្ចប់តែកិច្ចសន្យាការ

ងារតែប៉ុណ្ណោះ ដោយអនុវត្តតាមប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ និងមិនអាចដោះស្រាយដាច់ដោយឡែកពីវិវាទការងាររួមនេះបានឡើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ២៦២ កប/អក/វក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១០ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា លេខ ១១០/០១០ សសកពក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់មក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាចុងក្រោយ នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១០ ដោយទទួលលទ្ធផលមិនសះជានឹងគ្នាចំនួន ០៦ ចំណុច លើការទាមទារចំនួន ១៨ ចំណុច ។ ចំណុចមិនសះជាទាំង ០៦ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ២៦២ ក.ប/អក/វ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ មិញ ហ៊ុយ ហ្គាមេន (សហជីពមូលដ្ឋាន) មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៦ ចំណុចនេះ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង ១៤:០០

THE ARBITRATION COUNCIL

នាទីល្ងាច។ ភាគីក្រុមហ៊ុនបានអញ្ជើញមកចូលរួមសវនាការ តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដោយឡែកភាគីថ្នាក់ដឹកនាំសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ មិញ ហ៊ុយ ហ្គាមេន ក៏ដូចជាកម្មករនិយោជិតដែលជាដើមបណ្តឹង មិនបានអញ្ជើញចូលរួមសវនាការតាមការកោះអញ្ជើញឡើយ គឺមានតែលោក ប៉ាវ ស៊ីណា និង លោក ហ្វា សាលី ជាមន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា តែប៉ុណ្ណោះ ដែលបានមកចូលរួម។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចលើករណីនេះ ដូចខាងក្រោម:

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៥ ។

២- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៥ ។

៣- លក្ខន្តិកៈក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៥ ។

៤- កិច្ចសន្យាការងាររវាងក្រុមហ៊ុន មិញ ហ៊ុយ និង ឈ្មោះ ប៉ុក ហាវ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១០។

៥- លិខិតបំពេញប្រវត្តិរូបស្នើសុំការងាររបស់ឈ្មោះ ប៉ុក ហាវ ។

៦- កិច្ចសន្យាសុំបំរើការងារឈ្មោះ ប៉ុក ហាវ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១០ ។

៧- លក្ខខ័ណ្ឌការងារសម្រាប់កម្មករនិយោជិតចូលបំរើការងារក្នុងក្រុមហ៊ុន មិញ ហ៊ុយ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១០ ។

៨- កិច្ចព្រមព្រៀងបំរើការងាររបស់ឈ្មោះ ប៉ុក ហាវ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១០ ។

៩- កិច្ចសន្យាការងាររវាងក្រុមហ៊ុន មិញ ហ៊ុយ និង ឈ្មោះ សៀក ដា ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០។

១០- លិខិតបំពេញប្រវត្តិរូបស្នើសុំការងាររបស់ឈ្មោះ សៀក ដា ។

១១- កិច្ចសន្យាសុំបំរើការងារឈ្មោះ សៀក ដា ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ។

១២- លក្ខខ័ណ្ឌការងារសម្រាប់កម្មករនិយោជិតចូលបំរើការងារក្នុងក្រុមហ៊ុន មិញ ហ៊ុយ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ។

១៣- កិច្ចព្រមព្រៀងបំរើការងាររបស់ឈ្មោះ សៀក ដា ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ ។

១៤- អនុសញ្ញារួមស្ដីពីការបើកប្រាក់ឈ្នួលរវាងក្រុមហ៊ុន មិញ ហ៊ុយ និងប្រតិភូពេញសិទ្ធិ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ ។

១៥- សេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៥ ។

១៦- កិច្ចសន្យាការងាររវាងក្រុមហ៊ុន មិញ ហ៊ុយ និងឈ្មោះ រ៉េន ចិន ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០។

១៧- លិខិតបំពេញប្រវត្តិរូបស្នើសុំការងាររបស់ឈ្មោះ រ៉េន ចិន ។

១៨- កិច្ចសន្យាសុំបំរើការងារឈ្មោះ រ៉េន ចិន ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០ ។

១៩- លក្ខខ័ណ្ឌការងារសម្រាប់កម្មករនិយោជិតចូលបំរើការងារក្នុងក្រុមហ៊ុន មិញ ហ៊ុយ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០ ។

២០- កិច្ចព្រមព្រៀងបំរើការងាររបស់ឈ្មោះ រ៉េន ចិន ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១០ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករនៃរោងចក្រ មិញ ហ៊ុយ ហ្គាមេន ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ ។

២- សារណាពាក់ព័ន្ធសំណុំរឿងរោងចក្រកាត់ដេរ មិញ ហ៊ុយ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ ។

៣- កំណត់ហេតុស្ដីពីការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន មិញ ហ៊ុយ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១០។

៤- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្ដីពីការប្ដឹងនាយកក្រុមហ៊ុន មិញ ហ៊ុយ រើសអើងសេរីភាពសហជីព ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ។

៥- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្ដីពីការប្ដឹងនាយកក្រុមហ៊ុន មិញ ហ៊ុយ មិនអនុវត្តច្បាប់ការងារ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០ ។

៦- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា គោរពជូនលោកនាយកក្រុមហ៊ុន មិញ ហ៊ុយ ស្ដីពីការណាត់ជួបលោកនាយកពិភាក្សាដោះស្រាយលក្ខខណ្ឌការងារ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ ។

៧- លិខិតអន្តរាគមន៍របស់ថ្នាក់ដឹកនាំសហជីពសេរីកម្មករ និងកម្មករ-កម្មការិនីប្រចាំរោងចក្រ មិញ ហ៊ុយ គោរពជូនលោកប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ស្ដីពីការដោះស្រាយលក្ខខណ្ឌការងារ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០ ។

៨- លក្ខន្តិកៈសហជីពសេរីកម្មករនៃរោងចក្រ មិញ ហ៊ុយ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ។

៩- លិខិតលើកពេលផ្សះផ្សា ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន មិញ ហ៊ុយ លេខ ២៦២ កប/អក/វក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន មិញ ហ៊ុយ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១៦៩ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១៧០ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់ភាគីកម្មករនិយោជិត និង និយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

-ភាគីក្រុមហ៊ុនបានអញ្ជើញមកចូលរួមសវនាការ តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដោយឡែកភាគីថ្នាក់ដឹកនាំសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ មិញ ហ៊ុយ ហ្គាមេន ក៏ដូចជាកម្មករនិយោជិត ដែលជាដើមបណ្តឹងមិនបានអញ្ជើញចូលរួមសវនាការ តាមការកោះអញ្ជើញឡើយ គឺមានតែលោក ប៉ាវ ស៊ីណា និងលោក ហ្វា សាលី ដែលជាមន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ ដែលបានអញ្ជើញមកចូលរួមសវនាការ។ លោក ប៉ាវ ស៊ីណា និងលោក ហ្វា សាលី មិនមានលិខិតផ្ទេរសិទ្ធិពីសហជីពសេរីកម្មករប្រចាំរោងចក្រ ឱ្យធ្វើជាតំណាងដើម្បីមកដោះស្រាយវិវាទ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ គឺមានតែលិខិតរបស់កម្មករនិយោជិតសុំឱ្យសហជីពសេរីកម្មករព្រះរាជាណាចក្រកម្ពុជាជួយធ្វើអន្តរាគមន៍តែប៉ុណ្ណោះ។

-លោក ប៉ាវ ស៊ីណា បានបញ្ជាក់នៅក្នុងសវនាការថា នៅមុនថ្ងៃសវនាការពីរបីថ្ងៃ ថ្នាក់ដឹកនាំសហជីពមូលដ្ឋានបានទូរស័ព្ទទាក់ទងមកលោក ដើម្បីសាកសួរពីស្ថានភាពសំណុំរឿងនេះ។ លោក ប៉ាវ ស៊ីណា

បានប្រាប់ទៅសហជីពមូលដ្ឋានថា សវនាការនៃសំណុំរឿងនេះ នឹងប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១០ វេលាម៉ោង ១៤:០០ នាទីល្ងាច។ សហជីពមូលដ្ឋានបានសន្យាថា នឹងផ្តល់លេខទូរស័ព្ទរបស់គាត់ ដល់លោក ប៉ាវ ស៊ីណា ដើម្បីអាចធ្វើការទំនាក់ទំនងទាក់ទងនឹងសំណុំរឿងនេះបាន ប៉ុន្តែសហជីពមូលដ្ឋាន មិនដែលបានផ្តល់លេខទូរសព្ទនោះទេ។ ហេតុនេះ មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាមិនអាចទាក់ទងថ្នាក់ដឹកនាំសហជីពមូលដ្ឋាន និងកម្មករនិយោជិតនៅក្នុងវិវាទនេះបានទេ។

- លោក ប៉ាវ ស៊ីណា និងលោក ហ្វា សាលី បានបញ្ជាក់ដែរថា ពួកគាត់មកចូលរួមសវនាការនេះ គឺដើម្បីសុំពន្យាពេលសវនាការ ពីព្រោះថ្នាក់ដឹកនាំសហជីពសេរីកម្មករប្រចាំរោងចក្រ ត្រូវបានក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារអស់ហើយ ហើយពួកគាត់មិនអាចទាក់ទងបានទេ ដោយសារថ្នាក់ដឹកនាំសហជីពមូលដ្ឋានបានផ្លាស់ប្តូរទីលំនៅ និងមិនមានលេខទូរសព្ទសម្រាប់ទាក់ទង។ លើសពីនេះ កម្មករនិយោជិតដែលធ្វើការទាមទារនេះ ក៏មិនអាចទាក់ទងឱ្យមកចូលរួមសវនាការបានដែរ។
- ភាគីក្រុមហ៊ុនមានតំណាងជារដ្ឋបាលរបស់ក្រុមហ៊ុនបានចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយមានលិខិតផ្ទេរសិទ្ធិ ពីលោកនាយកក្រុមហ៊ុន មិញ ហ៊ុយ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០។ លោក ប៉ាវ ស៊ីណា និងលោក ហ្វា សាលី មិនមានការជំទាស់ចំពោះសមាសភាពនៃអ្នកតំណាងនេះទេ។ ចំពោះការស្នើសុំលើកពេលសវនាការដោយលោក ប៉ាវ ស៊ីណា និងលោក ហ្វា សាលី នេះ ត្រូវបានភាគីក្រុមហ៊ុនជំទាស់ ដោយបញ្ជាក់ថា លោក ប៉ាវ ស៊ីណា និងលោក ហ្វា សាលី មិនមានលិខិតផ្ទេរសិទ្ធិពីសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ មិញ ហ៊ុយ ហ្គាមេន ឱ្យធ្វើជាតំណាងកម្មករនិយោជិតមកដោះស្រាយវិវាទ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។

## ហេតុផលនៃសេចក្តីសម្រេច

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិតអន្តរាគមន៍ ដែលធ្វើឡើងដោយថ្នាក់ដឹកនាំសហជីពសេរីកម្មករ និងកម្មករនិយោជិតប្រចាំរោងចក្រ មិញ ហ៊ុយ ដោយស្នើសុំលោកប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាជួយធ្វើអន្តរាគមន៍ និងដោះស្រាយវិវាទ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០។ ផ្អែកលើខ្លឹមសារនៃលិខិតនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដើមបណ្តឹងដែលទាមទារ គឺកម្មករនិយោជិត និងសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ មិញ ហ៊ុយ ហ្គាមេន។ ប៉ុន្តែនៅថ្ងៃសវនាការ ថ្នាក់ដឹកនាំសហជីព និងកម្មករនិយោជិតប្រចាំរោងចក្រ មិញ ហ៊ុយ មិនបានមកចូលរួមសវនាការទេ (អវត្តមានដោយគ្មានមូលហេតុ) គឺមានតែមន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ដែលបានមកចូលរួម

THE ARBITRATION COUNCIL

ហើយបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលពន្យាពេលសវនាការ។ ភាគីតំណាងក្រុមហ៊ុនមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវពីនាយកក្រុមហ៊ុន ហើយបានជំទាស់ពីភាពជាតំណាងរបស់ភាគីកម្មករនិយោជិត។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើមន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិស្របច្បាប់ដើម្បីធ្វើជាតំណាងឱ្យកម្មករនិយោជិត និងសហជីពមូលដ្ឋាន ដែលជាអ្នកទាមទារនៅក្នុងវិវាទនេះ ដោយគ្មានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរដែរ រឺទេ?

ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា " *ភាគីវិវាទអាចមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវីដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀតដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ* "។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២០/០៧-ស្ការ នីតធីង ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបកស្រាយថា ប្រការ ១៩ នៃប្រកាសលេខ ០៩៩ ខាងលើ បញ្ជាក់ច្បាស់លាស់ថា អ្នកដែលមកតំណាងឱ្យភាគីវិវាទ ត្រូវទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ។

នៅក្នុងករណីនេះ សហជីពសេរីកម្មករប្រចាំរោងចក្រ មិញ ហ៊ុយ និងសមាជិកសហជីព ដែលជាភាគីដើមបណ្តឹង នៅក្នុងសំណុំរឿងនេះ មិនបានពឹងពាក់ និងផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនមន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា គឺលោក ប៉ាវ ស៊ីណា និងលោក ហ្វា សាលី ដើម្បីឱ្យជួយដោះស្រាយវិវាទការងារនេះឡើយ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មន្ត្រីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ពុំមានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យសហជីពមូលដ្ឋាន និងសមាជិកសហជីពនៅក្នុងវិវាទក្នុងការដោះស្រាយវិវាទការងារនេះទេ។

ប្រការ ២១ នៃប្រកាសលេខ ០៩៩ ចែងថា " *ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយតែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់* "។

ក្នុងករណីនេះ ភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងបានអវត្តមាន ដោយមិនមានមូលហេតុត្រឹមត្រូវ ហើយក៏មិនបានបញ្ជូនតំណាងស្របច្បាប់ ដែលមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានជូនដំណឹងត្រឹមត្រូវទៅភាគីវិវាទ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ អំពីកាលបរិច្ឆេទនៃសវនាការ ដែលត្រូវធ្វើនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ រួចហើយ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ជាទូទៅ ដើមបណ្ដឹងមានកាតព្វកិច្ចផ្ដល់ហេតុផល និងភស្ដុតាង នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីការពារបណ្ដឹងរបស់ខ្លួន។ ប៉ុន្ដែក្នុងសំណុំរឿងនេះ ភាគីសហជីពសេរីកម្មករប្រចាំរោងចក្រ ដែលជាភាគីដើមបណ្ដឹង មិនបានចូលរួមក្នុងសវនាការដើម្បីផ្ដល់នូវហេតុផល និងភស្ដុតាង ដើម្បីការពារបណ្ដឹងរបស់ខ្លួនទេ ហើយការមិនមកចូលរួមសវនាការនោះក៏មិនបានបញ្ជាក់ពីហេតុផលច្បាស់លាស់ដែរ។ ក្នុងករណី ភាគីដើមបណ្ដឹងមិនមកបង្ហាញខ្លួន ឬចាត់អ្នកតំណាងត្រឹមត្រូវ ក្នុងដំណើរការអាជ្ញាកណ្ដាលធ្វើឱ្យភាគីបាត់បង់ឱកាសក្នុងការផ្ដល់ហេតុផល និងភស្ដុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការដែលសហជីពសេរីកម្មករប្រចាំរោងចក្រមិនបានមកបង្ហាញខ្លួន ឬមិនបានចាត់អ្នកតំណាង ដែលមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរក្នុងដំណើរការអាជ្ញាកណ្ដាលនេះ គឺសហជីពបានបោះបង់ការទាមទាររបស់ខ្លួន។

ដូច្នេះ ក្រុមប្រឹក្សាសម្រេចបិទសំណុំរឿងលេខ ២៩/១០-មិញ ហ៊ុយ នេះ។

យោងតាមការបង្ហាញភស្ដុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ដូចតទៅ :

## សម្រេច និង បង្គាប់

សម្រេចបិទសំណុំរឿង លេខ ២៩/១០-មិញ ហ៊ុយ ហ្គាមេន។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : កៅ ថាច

ហត្ថលេខា: ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : អន ណាន

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : ម៉េន ប៊ុនណារ

ហត្ថលេខា: ------------------------------